អន្តរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ មុខងាររបស់រដ្ឋសភាជាអំណាចនីតិបញ្ញត្តិក្នុងរបបប្រជាធិបតេយ្យ

website : www.hoksavann.org

ថ្ងៃទី២ មេសា ២០០៧



ក្នុងប្រទេសដែលកាន់របបប្រជាធិបតេយ្យ គេតែងចែកអំណាចទាំងបី គឺអំណាចនីតិបញ្ញត្តិបានដល់រដ្ឋសភា អំណាចនីតិប្រតិបត្តិបានដល់រដ្ឋាភិបាល និងអំណាចតុលាការឲ្យដាច់ដោយឡែកពីគ្នា មានភាពឯករាជ្យរៀងខ្លួន ។ ចំពោះអំណាចរដ្ឋសភាជាអង្គការនីតិបញ្ញត្តិ មានមុខងារសំខាន់ៗ គឺអនុម័តច្បាប់ តែងតាំងរដ្ឋាភិបាល ឃ្លាំមើលសកម្មភាពរបស់រដ្ឋាភិបាល កោះហៅរដ្ឋមន្ត្រីណាដែលប្រព្រឹត្តខុសខូចប្រយោជន៍ជាតិមកសាកសួរដេញដោល ហើយអាចបោះឆ្នោតទម្លាក់បើមានកំហុសធ្ងន់ជាដើម ។ មុខងារដ៏សំខាន់មួយទៀត គឺទៅសួរសុខទុក្ខប្រជាពលរដ្ឋនៅក្នុងមណ្ឌលរបស់ខ្លួន ជួយដោះស្រាយរាល់បញ្ហារបស់ប្រជាពលរដ្ឋ ។ សមាជិកសភាទាំងអស់ជាសភាជាតិ ធ្វើការបំរើជាតិ ពុំមែនបំរើគណបក្សនីមួយៗឡើយ ។

ក្រឡេកមកមើលរដ្ឋសភានៃរាជាណាចក្រកម្ពុជាជិតបីអាណត្តិ ចាប់ពីឆ្នាំ១៩៩៣រហូតដល់ឆ្នាំ២០០៧នេះ គេឃើញតែធ្វើតាមរាជរដ្ឋាភិបាលគ្រប់បញ្ហា ដែលរដ្ឋាភិបាលបានធ្វើសំណើមកតែងតែអនុម័តយល់ព្រមគ្មានជំទាស់ ។ ដូចការអនុម័តលើរដ្ឋាភិបាលកញ្ចប់ លើសន្ធិសញ្ញាបំពេញបន្ថែមទៅលើសន្ធិសញ្ញាឆ្នាំ១៩៨៥ជាដើម ។ ចំពោះសមាជិកសភានៃគណបក្សប្រជាជន ដែលជាគណបក្សកាន់អំណាចពេលប្រជុំសភាម្តងៗ ដើម្បីពិភាក្សាអំពីសំណើររបស់រាជរដ្ឋាភិបាល គ្មានឃើញឡើងនិយាយជំទាស់នឹងសំណើរបស់រាជរដ្ឋាភិបាលត្រង់ខណាមួយឡើយ បើមានឡើងនិយាយវិញ ឬតែសរសើរហៃអើចំពោះសំណើនោះទៅវិញ ។ ឯសមាជិកសភានៃគណបក្សហ៊្វុនស៊ិនប៉ិច ដែលជាគណបក្សធ្វើរដ្ឋាភិបាលចំរុះជាមួយគណបក្សប្រ

ជាជនកម្ពុជា មានឡើងនិយាយបញ្ចេញយោបល់ខ្លះ ប៉ុន្តែត្រូវឡប់ពីការប្រជុំវិញ ទ្រង់រណឫទ្ធិដែលពេលនោះជាប្រធានរដ្ឋសភា បានហៅមកហាមកុំឲ្យមានមតិអ្វីច្រើនពេក ដើម្បីកុំឲ្យមានភាពកកករល្អក់ក្នុងរដ្ឋាភិបាលចំរុះ ។ ផ្ទុយទៅវិញ សមាជិកសភានៃគណបក្សសម-រង្ស៊ីតែងតែរៀបចំខ្លួនស្រាវជ្រាវរកហេតុផល នូវគ្រប់សំណើរបស់រាជរដ្ឋាភិបាល ហើយឡើងនិយាយជំទាស់ត្រង់ខខ្លះនៃសំណើនោះ ប៉ុន្តែមតិជំទាស់នោះមិនជាទីពេញចិត្តនៃសមាជិកសភានៃគណបក្សប្រជាជនឡើយ ។ មានពេលខ្លះ សមាជិកសភានៃគណបក្សប្រជាជនបានឡើងនិយាយចំអក និងប្រឆាំងនឹងមតិរបស់សមាជិកសភានៃគណបក្សសម-រង្ស៊ី ដែលនិយាយជំទាស់នឹងសំណើរបស់រាជរដ្ឋាភិបាល ។ ដូច្នេះបញ្ជាក់ថា សមាជិកសភានៃគណបក្សប្រជាជនចាំតែគាំទ្រសំណើរបស់រាជរដ្ឋាភិបាល ហើយការពារមិនឲ្យមានមតិជំទាស់ ។ អំពើបែបនេះចាត់ទុកថាសមាជិកសភានៃគណបក្សប្រជាជន ជាសភារបស់គណបក្ស ពុំមែនជាសភាសំរាប់ជាតិខ្មែរទាំងមូលឡើយ ។ លក្ខណៈរបស់រដ្ឋសភាខ្មែរដូចបានពោលមកនេះ ដែលមិនបានបំពេញភារកិច្ចតាមមុខងាររបស់ខ្លួន មានគ្រោះថ្នាក់ដល់ជាតិធ្ងន់ណាស់ ដូចជាការធ្វើសច្ចានុម័តទៅលើសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ១៩៨៥ ដែលបានស្នើឡើងដោយរាជរដ្ឋាភិបាល ហើយមិនបានពិចារណាឲ្យបានល្អិតល្អន់ ដែលអាចធ្វើឲ្យខ្មែរបាត់បង់ទឹកដី ។ ច្បាប់ចម្លែកមួយដែលប្រទេសប្រជាធិបតេយ្យមិនដែលធ្វើ គឺរដ្ឋសភាខ្មែរបានអនុម័តច្បាប់ក៏រឹតសេរីភាពនិយាយស្តីក្នុងរដ្ឋសភារបស់សមាជិកសភា គឺគេអាចចាប់ដោះមិនចាំបាច់ដកអភ័យឯកសិទ្ធិជាមុន ចំពោះសមាជិកសភារូបណា និយាយឲ្យប៉ះពាល់ដល់កិត្តិយសបុគ្គល គឺជាច្បាប់ចងខ្លួនឯង ។ ច្បាប់នេះទំនងជាស្នើឡើងដោយរាជរដ្ឋាភិបាល ដើម្បីខ្ទប់មាត់គណបក្សប្រឆាំង ។ រដ្ឋសភាខ្មែរដែលមិនបានបំពេញមុខងារខ្លួនក្នុងភាពឯករាជ្យនេះហើយ បានជាមានមតិចោទថា រដ្ឋសភាខ្មែរគ្រាន់តែបំពេញកិច្ចសំរាប់ប្រថាប់ត្រាឲ្យរាជរដ្ឋាភិបាលប៉ុណ្ណោះ និងចោទថារដ្ឋសភាខ្មែរជាអាយ៉ងរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះ ។ រដ្ឋសភាខ្មែរត្រូវតែកែនូវអំពើខុសឆ្គងរបស់ខ្លួន ដើម្បីអភិវឌ្ឍន៍ប្រទេសកម្ពុជាឲ្យបានលូតលាស់ចំរើនស្របតាមរបបប្រជាធិបតេយ្យ ។ កុំធ្វើតាមសភារបស់របបកុម្មុយនិស្ត ដែលចាំតែសំរេចតាមមជ្ឈឹមបក្ស ។ មួយទៀត កុំធ្វើតាមសភារបស់របបផ្តាច់ការ ដែលចាំតែធ្វើតាមជនផ្តាច់ការ ។ បើផ្តាច់ការហើយ មានជនបរទេសនៅពីក្រោយទៀត នោះនឹងធ្វើឲ្យប្រទេសវិនាសពិតប្រាកដណាស់ ។ លក្ខណៈរបស់សភាជាតិ គឺអនុម័តច្បាប់ដើម្បីប្រយោជន៍ជាតិ ហើយទាត់ចោលនូវច្បាប់ដែលមិនមានលក្ខណៈត្រឹមត្រូវប្រកបដោយយុត្តិធម៌ ទោះបីច្បាប់នោះស្នើមកពីរដ្ឋាភិបាល ដែលចេញពីបក្សរបស់ខ្លួនក៏ដោយ ។៚

❄